**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

*ថ្ងៃ ព្រហស្បតិ៍ ១២ រោច ខែ មាឃ ឆ្នាំ ថោះ បញ្ចស័ក ព.ស.២៥៦៧*
*រាជធានីភ្នំពេញ ថ្ងៃទី ៧ ខែ មីនា ឆ្នាំ ២០២៤*

# សេចក្តីប្រកាសព័ត៌មានស្តីពី
## ស្តីពីលទ្ធផលនៃកិច្ចប្រជុំលើកទី៤ គណៈកម្មាធិការដឹកនាំគម្រោងបញ្ជរតែមួយជាតិ

នាព្រឹកថ្ងៃទី ៧ ខែ មីនា ឆ្នាំ ២០២៤, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំគម្រោងបញ្ជរតែមួយជាតិ បានដឹកនាំកិច្ចប្រជុំគណៈកម្មាធិការដឹកនាំគម្រោងបញ្ជរតែមួយជាតិលើកទី ៤ ដោយមានការអញ្ជើញចូលរួមពីតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ វិស័យឯកជន និងតំណាងដៃគូអភិវឌ្ឍន៍ ដើម្បីពិនិត្យអំពី ***"វឌ្ឍនភាពនៃការអនុវត្តគម្រោងបញ្ជរតែមួយជាតិដំណាក់កាលទី ៣"*** ដែលត្រូវបានប្រកាសដាក់ឱ្យអនុវត្តក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការដឹកនាំគម្រោងបញ្ជរតែមួយជាតិ លើកទី ៣ កាលពីថ្ងៃទី ៣ ខែ មករា ឆ្នាំ ២០២៣ និងមានរយៈពេលអនុវត្តចំនួន ១២ ខែ កន្លងមក ។

**"ប្រព័ន្ធបញ្ជរតែមួយជាតិ"** គឺពាក់ព័ន្ធនឹងការចេញអាជ្ញាប័ណ្ណ, វិញ្ញាបនបត្រ, លិខិតអនុញ្ញាត និងឯកសារផ្សេងទៀត ក្នុងទម្រង់អេឡិកត្រូនិក សម្រាប់ទំនិញនាំចេញ-នាំចូល ដែលស្ថិតក្នុងបញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់ ព្រមទាំង ទំនិញដែលទទួលបានការលើកលែងពន្ធនិងអាករស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។ **"គម្រោងបញ្ជរតែមួយជាតិ ដំណាក់កាលទី ៣"** បានពង្រីកវិសាលភាពទៅក្រសួង-ស្ថាប័នចំនួន ១១ បន្ថែមទៀត ។ ទន្ទឹមនេះ **"ប្រព័ន្ធបញ្ជរតែមួយជាតិ"** ក៏បានបន្ថែមមុខងារថ្មីចំនួន ៤ រួមមាន មុខងារគ្រប់គ្រងហានិភ័យ, មុខងារនិហិតដ្ឋានឯកសារពាណិជ្ជកម្ម, មុខងារប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត និងមុខងារគ្រប់គ្រងគណនីប្រើប្រាស់តែមួយ ។

អង្គប្រជុំ បានវាយតម្លៃខ្ពស់ និងកត់សម្គាល់លើវឌ្ឍនភាពនៃការអនុវត្តគម្រោង ដែលក្រសួង-ស្ថាប័នចំនួន ៦ រួមមាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងបរិស្ថាន, ក្រសួងរ៉ែនិងថាមពល, ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ, ធនាគារជាតិនៃកម្ពុជា, ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ បានចូលរួមអនុវត្ត

សាកល្បងប្រើប្រាស់ប្រព័ន្ធបញ្ជរតែមួយជាតិ ចាប់ពីថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០២៣ កន្លងមក និងក្រសួង-ស្ថាប័នមួយចំនួន បានត្រៀមលក្ខណៈសម្បត្តិរួចរាល់ដើម្បីចូលរួមអនុវត្តប្រព័ន្ធបញ្ជរតែមួយជាតិនាពេលដ៏ខ្លីខាងមុខ ។

ផ្អែកតាមវឌ្ឍនភាពសម្រេចបានខាងលើ និងតាមរយៈការពិភាក្សារបស់អង្គប្រជុំ, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** បានវាយតម្លៃខ្ពស់ចំពោះក្រសួង-ស្ថាប័ន ដែលចូលរួមអនុវត្ត **"ប្រព័ន្ធបញ្ជរតែមួយជាតិ"** បានពេញលេញ និងស្នើដល់ក្រសួង-ស្ថាប័នដែលចូលរួមពុំទាន់ពេញលេញ ឬពុំទាន់បានចូលរួមអនុវត្ត ឱ្យខិតខំនិងផ្តល់កិច្ចសហការប្រកបដោយស្មារតីបុរេសកម្ម អនុវត្តគម្រោងបញ្ជរតែមួយជាតិដំណាក់កាលទី ៣ ឱ្យបានជោគជ័យ ស្របតាមពេលវេលាដែលបានកំណត់ ។

ជាទីបញ្ចប់, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំគម្រោងបញ្ជរតែមួយជាតិ ក៏បានវាយតម្លៃខ្ពស់ចំពោះការចូលរួមផ្តល់មតិយោបល់ និងជាពិសេស ការបង្ហាញនូវការប្តេជ្ញា និងឆន្ទៈខ្ពស់ក្នុងការអនុវត្ត **"ប្រព័ន្ធបញ្ជរតែមួយជាតិ"** ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់របស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ដែលបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការធ្វើឱ្យប្រសើរឡើងនៃសេវាសារធារណៈ និងកិច្ចសម្រួលពាណិជ្ជកម្ម ក៏ដូចជាលើកកម្ពស់បរិយាកាសធុរកិច្ចនៅកម្ពុជាឲ្យកាន់តែល្អប្រសើរ ។